មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

Cambodian Center for Human Rights

# ស្ថានភាពសិទ្ធិមនុស្សប្រចាំត្រីមាសទី២

## ខែមេសា ដល់ខែមិថុនា ឆ្នាំ២០២៦

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានតាមដានករណីនៃការរំលោភបំពាន និងការរឹតត្បិតសិទ្ធិមនុស្សចំនួន ៤១ ករណី។ ករណីទាំងនេះរួមមាន ការរំលោភលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិមានសេរីភាព ព្រមទាំងសិទ្ធិដីធ្លី និងសិទ្ធិមិនទទួលរងនូវការមិនរើសអើង។ ក្នុងអំឡុងពេលនេះ ម.ស.ម.ក បានសង្កេតឃើញថា សេរីភាពក្នុងការបញ្ចេញមតិនៅតែបន្តរងការរឹតត្បិតយ៉ាងខ្លាំង ជាពិសេសពាក់ព័ន្ធនឹងការបញ្ចេញមតិតាមប្រព័ន្ធអនឡាញ។ អ្នកប្រើប្រាស់បណ្តាញសង្គមនៅតែបន្តប្រឈមមុខនឹងការយាយីតាមផ្លូវច្បាប់ចំពោះការចែករំលែកទស្សនៈផ្ទាល់ខ្លួនរបស់ពួកគេ ជាពិសេសពាក់ព័ន្ធនឹងជម្លោះព្រំដែនកម្ពុជា-ថៃ។

## ខាងក្រោមនេះ គឺជាទិដ្ឋភាពទូទៅនៃការរំលោភបំពានដែលត្រូវបានកត់ត្រាដោយ ម.ស.ម.ក៖

### សេរីភាពខាងការបញ្ចេញមតិ

ម.ស.ម.ក បានកត់ត្រាចំនួន ២៣ ករណី ដែលពាក់ព័ន្ធនឹងការរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ក្នុងចំណោមករណីទាំងនេះ ៧ ករណីបានកើតឡើងលើអ្នកប្រើប្រាស់បណ្តាញសង្គមដែលបានបញ្ចេញទស្សនៈរបស់ពួកគេតាមអនឡាញ ដោយក្នុងនោះ ៤ ករណីត្រូវបានរងការចោទប្រកាន់តាមផ្លូវច្បាប់ និង ៣ ករណីទៀតត្រូវបានផ្តន្ទាទោស។

ករណីចំនួនពីរ ក្នុងចំណោមករណីទាំងនេះ ពាក់ព័ន្ធនឹងអ្នកប្រើប្រាស់បណ្តាញសង្គមដែលបានបញ្ចេញទស្សនៈតាមអនឡាញអំពីការដោះស្រាយរបស់រាជរដ្ឋាភិបាលកម្ពុជាលើជម្លោះកម្ពុជា-ថៃ។ ក្នុងនោះ ម្នាក់ត្រូវបានផ្តន្ទាទោស ឯម្នាក់ទៀតត្រូវបានបដិសេធឱ្យនៅក្រៅឃុំ។ តុលាការកំពូលក៏បានតម្កល់ទោស «បទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មាន ជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ» និងទោសពន្ធនាគារ ១៤ ឆ្នាំ លើអ្នកសារព័ត៌មានពីររូបផងដែរ។

### សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា

មានមួយករណីគឺពាក់ព័ន្ធនឹងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ អ្នកស្រឡាញ់ភេទដូចគ្នាម្នាក់ត្រូវបានចាប់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នដើម្បីរង់ចាំការជំនុំជម្រះ ជាការឆ្លើយតបទៅនឹងការបង្ហោះសារលើ បណ្តាញសង្គមរបស់គាត់បន្ទាប់ពីត្រូវនគរបាលវាស់កម្រិតអាល់កុល។ បន្ថែមពីលើការចោទប្រកាន់ពីបទញុះញង់ និងប្រមាថអ្នករាជការសារធារណៈ គាត់ក៏ត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈពាក់ព័ន្ធនឹងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់គាត់ ដែលបញ្ជាក់ពីភេទដើមពីកំណើតជាប្រុស ខណៈដែលប័ណ្ណបើកបររបស់គាត់បញ្ជាក់ជាភេទស្រីទៅវិញ។ ការចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈនេះ ដោយសារកម្ពុជាពុំទាន់មានច្បាប់ទទួលស្គាល់អត្តសញ្ញាយេនឌ័រតាមការកំណត់របស់បុគ្គលជាពិសេសអ្នកប្តូរយេនឌ័រនៅឡើយ។

### សិទ្ធិដីធ្លី និងការបណ្តេញចេញដោយបង្ខំ

ករណីចំនួន ១៦ គឺពាក់ព័ន្ធនឹងសិទ្ធិលំនៅដ្ឋាននិងសិទ្ធិដីធ្លី ព្រមទាំងការកេងប្រវ័ញ្ចធនធានធម្មជាតិ ជាពិសេសការរំលោភយកដីធ្លី។ ក្នុងចំណោមករណីទាំងនេះ ៧ ករណីគឺពាក់ព័ន្ធនឹងក្រុមហ៊ុនឯកជនដែលបានធ្វើសកម្មភាពរំលោភយកដីធ្លី ការកាប់ឆ្ការព្រៃឈើ ឬការរុករករ៉ែ។ មានជាច្រើនករណីដែលរាជរដ្ឋាភិបាលកម្ពុជាបានជួយសម្របសម្រួលដល់សកម្មភាពទាំងនោះ ព្រមទាំងខកខានក្នុងការអន្តរាគមន៍និងជួយជនរងគ្រោះ តែបានផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឱ្យក្រុមហ៊ុនទាំងនោះទៅវិញ។ ក្នុងចំណោមករណីដែលត្រូវបានកត់ត្រាចំនួន ៥ ករណី ជនរងគ្រោះនៃសកម្មភាពទាំងនេះ <u>គឺជាសហគមន៍ជនជាតិដើមភាគតិច</u>។

### សិទ្ធិមានសេរីភាព

ករណីចំនួនពីរគឺពាក់ព័ន្ធនឹងសិទ្ធិទទួលបានសេរីភាព ដែលក្នុងនោះបុគ្គលត្រូវបានបដិសេធឱ្យនៅក្រៅឃុំ និងបន្តស្ថិតក្រោមការឃុំខ្លួន ពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិមូលដ្ឋានរបស់ពួកគេ ចំពោះសេរីភាពខាងការបញ្ចេញមតិ ការជួបជុំ និងការប្រមូលផ្តុំ។ ជាការកត់សម្គាល់ ការឃុំខ្លួនបុគ្គលម្នាក់សម្រាប់ការអនុវត្តសិទ្ធិទាំងនេះ បណ្តាលឱ្យការឃុំខ្លួននោះក្លាយជា "ការឃុំខ្លួនដោយអំពើចិត្ត" ក្រោមច្បាប់អន្តរជាតិ។

ករណីមួយទៀត សាលាឧទ្ធរណ៍ភ្នំពេញបានបដិសេធសំណើសុំនៅក្រៅឃុំរបស់ព្រះសង្ឃមួយអង្គ ដែលជាអ្នកសារព័ត៌មានពលរដ្ឋ ហើយដែលត្រូវបានចាប់ខ្លួនកាលពីខែមេសា ពាក់ព័ន្ធនឹងការចែករំលែកទស្សនៈតាមអនឡាញអំពីជម្លោះព្រំដែន។ តុលាការកំពូលក៏បានបដិសេធសំណើសុំនៅក្រៅឃុំរបស់អ្នកការពារសិទ្ធិមនុស្ស និងជាអនុប្រធានសមាគមសម្ព័ន្ធនិស្សិតបញ្ញវន្តខ្មែរផងដែរ ៕

CC BY NC SA

កក្កដា ២០២៦